ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

40
3

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី
លេខ: ៣៦១
ចុះថ្ងៃទី ១៩-៩-២០១១

សាលដីកា
លេខ: ៣៨ក្រ
ចុះថ្ងៃទី ១២-១១-២០១២

# គាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នាថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០១២

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ជាប្រធាន
ឯកឧត្តម ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

**ក្រឡាបញ្ជី**

លោកស្រី [redacted]

-ដើមចោទឈ្មោះ [redacted] វីនី ភេទស្រី អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ី មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១២៣AE0 ផ្លូវលេខ២២៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។
មេធាវី តំណាងដោយអាណត្តិលោក [redacted] ។

-ចុងចម្លើយឈ្មោះ [redacted] សុភាព ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីរាជការ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៧៣E0 ផ្លូវលេខ២០០៤ ក្រុមទី១៤ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] មុំ (ស) ម្ដាយឈ្មោះ [redacted] មុត (ស) ប្ដីឈ្មោះ [redacted] ស្រាយ មានកូន២នាក់ ។
មេធាវី តំណាងដោយអាណត្តិលោក [redacted] ។

**ខ្លឹមសារនៃការទាមទាររបស់ដើមចោទ**

-សុំប្ដឹងទាមទារប្រាក់ជំពាក់ពីឈ្មោះ [redacted] សុភាព ។

**អង្គហេតុ និងចំណុចវិវាទ**

១-សាលក្រមទាមទារដោយដើមចោទ :

ក-សុំរំលាយកិច្ចសន្យាជួលផ្ទះចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ខ-សុំអោយឈ្មោះ [redacted] សុភាព បង់ប្រាក់ចំនួន ១.២០០.០០០រៀល(មួយលានពីរសែនរៀល) ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១១ ។



Scanned with CamScanner

គ-ទាមទារថ្លៃចាក់ដីធ្វើដំបូលនិងថ្លៃទទឹក ៩១៦៣៥$ (ប្រាំបួនម៉ឺនមួយពាន់ប្រាំមួយរយសាមសិបប្រាំដុល្លាអាមេរិក) ។

ឃ-ទាមទារប្រាក់កក់ចំនួន ៤៨០០$ (បួនពាន់ប្រាំបីរយដុល្លាអាមេរិក)គុណនឹង៣ មកកូនក្តីខ្លួនឈ្មោះ [redacted] វីរីនី តាមកិច្ចសន្យាចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ង-សងជម្ងឺចិត្ត ការខាតបង់ពេលវេលាការចំណាយផ្សេងៗ រួមទាំងចំណាយសេវាមេធាវីជាប្រាក់ចំនួន ១០០.០០០$ (ដប់ម៉ឺនដុល្លាអាមេរិក) ។

ច-សុំអោយតុលាការប្រកាសថា សាលក្រមនេះអនុវត្តជាបណ្តោះអាសន្នបាន ។

ឆ-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ។

-ការអះអាងរបស់លោកមេធាវី [redacted] តំណាងដោយអាណត្តិអោយដើមចោទឈ្មោះ [redacted] វីរីនី បានថ្លែងការណ៍ថា កូនក្តីខ្លួនជាអ្នកប្តឹងរំលាយកិច្ចសន្យាដោយកូនក្តីខ្លួនបានជួលផ្ទះរយៈពេល៥ឆ្នាំ តម្លៃក្នុងមួយខែ៤០០ដុល្លា តែមិនទាន់អនុវត្តចប់ផងស្រាប់តែអ្នក ស្រី [redacted] សុភាព ជាអ្នកផ្តាច់ ទឹកនិងភ្លើង ធ្វើអោយការប្រកបអាជីវកម្មត្រូវអាក់ខាន ។ ក្រោយពីបានជួលផ្ទះកូនក្តីខ្លួនបាន កែលំអរជួសជុលសាងសង់អាគារចាក់ដីទាំងស្រុង សរុបទឹកប្រាក់ចំនួន ៩១៦៣៥ ដុល្លាអាមេរិក ហើយចោទកូនក្តីខ្លួនមិនបានបង់ប្រាក់ ។ ការផ្តាច់ទឹកនិងភ្លើង ធ្វើអោយកូនក្តីខាតបង់យ៉ាងធ្ងន់ធ្ងរក្នុងការប្រកបអាជីវកម្មបាត់ បង់ប្រាក់ចំណូលក្នុងមួយថ្ងៃចំនួន ១.២០០.០០០រៀល ។ សំណូមពរសូមអោយក្រុមប្រឹក្សាតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

-ចុងចម្លើយឈ្មោះ [redacted] សុភាព បានទទួលដីកាកោះត្រឹមត្រូវហើយនៅថ្ងៃទី ២០-១០-២០១២ តែអវត្តមានដោយគ្មានមូលហេតុ ហើយមេធាវីក៏មិនមានវត្តមានដែរ ។ ✓

## សំអាងហេតុ

យល់ឃើញថា :

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុភាព សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ០៤ក្រ២ "ណ" ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី២ ទី៥ នៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើកឡើងរឿងនេះយកមកជំនុំជម្រះ បានតាមបញ្ញត្តិច្បាប់ ។

២-ពេលទាញហេតុផលដោយផ្ទាល់មាត់លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទឈ្មោះ [redacted] វីរីនី បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនសុំប្តឹងរំលាយកិច្ចសន្យាចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយកូនក្តីខ្ញុំបានជួលផ្ទះពីឈ្មោះ [redacted] សុភាព មានរយៈពេល៥ឆ្នាំ ដោយមានតម្លៃក្នុងមួយខែបួនរយដុល្លា តែមិនទាន់អនុវត្តកិច្ចសន្យាចប់ផង ស្រាប់តែអ្នកស្រី [redacted] សុភាព បានផ្តាច់ទឹកនិងភ្លើង ធ្វើអោយការប្រកបអាជីវកម្មត្រូវអាក់ខាន ។ ក្រោយពីជួលផ្ទះកូនក្តីខ្លួនបានធ្វើការកែលំអជួសជុលសាងសង់ចាក់ដីធ្វើដំបូល និងទិញសំភារៈផ្សេងៗសម្រាប់ធ្វើអាជីវកម្មសំអាងការកាត់សក់ និងចំណាយផ្សេងៗទៀតអស់ចំនួន ៩១៦៣៥ដុល្លាអាមេរិក។ ការផ្តាច់ភ្លើងនិងទឹកធ្វើអោយកូនក្តីខ្លួន ខាតបង់យ៉ាងធ្ងន់ធ្ងរក្នុងការធ្វើអាជីវកម្ម បាត់បង់ប្រាក់ចំណូលក្នុងមួយថ្ងៃ ១,២០០.០០០រៀល។ ការដែលមេធាវីលើកឡើងនេះ សាលាដំបូងរាជធានីភ្នំពេញ បានពិចារណា



៣៧៨

៦៧៩

ពីសំណាងរួចហើយ សាលាឧទ្ធរណ៍ឯកភាព ដោយពុំចាំបាច់លើកសំអាងហេតុដដែលៗមកទៀតទេ ។

៣-ចុងចម្លើយឈ្មោះ [redacted] សុភាព បានទទួលដីកាកោះត្រឹមត្រូវហើយ នៅថ្ងៃទី ២០-១០-២០១២ តែមិនមានវត្តមានដោយគ្មានមូលហេតុ សាលាឧទ្ធរណ៍អាចជំនុំជម្រះបានដោយកំបាំងមុខឈ្មោះ [redacted] សុភាព ចាត់ទុកជាចំពោះមុខ ។ ហើយមេធាវីក៏មិនមានវត្តមានដែរ ។

៤-សាលក្រមរដ្ឋប្បវេណីលេខ ០៤ក្រ២"ណ" ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ហើយគប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមនេះទុកជាបានការ ។

## ទនិច្ឆ័យសេចក្ដី

១-ច្រានចោលបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] សុភាព ចោលជាអសារបង់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៤ក្រ២ "ណ" ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីឈ្មោះ [redacted] សុភាព អ្នកចាញ់ក្ដី ។

៤-សាលដីកានេះ ទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០១២ បើកផ្លូវប្ដឹងសាទុកក្នុងកំណត់០១ខែ គិតពីថ្ងៃទទួលការជូនដំណឹង ពីសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |

ហត្ថលេ[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញថ្ងៃទី០៩ ខែ12 ឆ្នាំ២០12

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

៣៧៩